អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

# អនុស្សរណៈអន្តរការិយាល័យ
# INTEROFFICE MEMORANDUM

ផ្ញើពី/From: ប្រធានអង្គជំនុំជម្រះតុលាការកំពូល ("ប្រធាន")

**President of the Supreme Court Chamber (the "President")**

ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០២២

Date: 02 August 2022

ផ្ញើជូន/To:
អង្គជំនុំជម្រះសាលាដំបូង
អង្គបុរេជំនុំជម្រះ
ការិយាល័យសហចៅក្រមស៊ើបអង្កេត
ការិយាល័យសហព្រះរាជអាជ្ញា
អង្គភាពផ្នែកគាំពារការការពារក្តី
សហមេធាវីការពារក្តី ខៀវ សំផន
អង្គភាពគាំពារជនរងគ្រោះ
អង្គភាពគាំពារសាក្សី និងអ្នកជំនាញ
សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី/មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ផ្នែកគ្រប់គ្រងតុលាការ
ប្រធានការិយាល័យរដ្ឋបាលស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល

Trial Chamber
Pre-Trial Chamber
Office of the Co-Investigating Judges
Office of the Co-Prosecutors
Defence Support Section
Co-Lawyers for the Accused KHIEU Samphân
Victims Support Section
Witness and Experts Support Unit
Civil Party Lead Co-Lawyers/Civil Party Lawyers

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-Aug-2022, 14:50
CMS/CFO: Sann Rada

Court Management Section

Acting Director and Deputy Director of Administration

**កម្មវត្ថុ/ Subject:** **ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២**

Review of Confidential and Strictly Confidential Documents on Case File 002.

## I. សេចក្តីផ្តើម

១. យោងតាមមាត្រា ១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ថ្នាក់ឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងទៅនឹងសំណុំរឿង (វិសោធនកម្មលើកទី១) ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ថ្នាក់ឯកសារ") អង្គជំនុំជម្រះតុលាការកំពូលដែលជាការិយាល័យតុលាការចុងក្រោយក្នុងការទទួលសំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក. (សំណុំរឿង ០០២) ត្រូវបានផ្តល់ភារកិច្ចក្នុងការពិនិត្យឡើងវិញនូវរាល់ឯកសារដែលត្រូវបានដាក់ចំណាត់បច្ចុប្បន្នជាសម្ងាត់ ឬសម្ងាត់បំផុតក្នុងសំណុំរឿង ០០២ សម្រាប់គោលបំណងនៃការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញដែលនឹងអាចទៅជាសាធារណៈ។ គោលបំណងនៃអនុស្សរណៈនេះ គឺដើម្បីបង្ហាញនូវនីតិវិធីជារួម និងគោលការណ៍ណែនាំដែលស្នើឡើង និងស្នើសុំការផ្តល់យោបល់ពីភាគីដែលមានចំណាប់អារម្មណ៍ពាក់ព័ន្ធទៅនឹងដំណើរការនៃការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញ។

២. អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវធ្វើការពិនិត្យឡើងវិញលើសំណុំរឿង ០០២ ជាបីដំណាក់កាល៖ ទីមួយ យោងតាមអនុស្សរណៈបច្ចុប្បន្ន អង្គជំនុំជម្រះតុលាការកំពូលបានលើកបង្ហាញនូវគោលការណ៍ណែនាំដែលស្នើឡើងសម្រាប់គោលបំណងក្នុងការអញ្ជើញភាគី អង្គភាព និងផ្នែកផ្សេងៗដែលពាក់ព័ន្ធ ផ្តល់យោបល់។ ទីពីរ បន្ទាប់ពីការពិនិត្យលើសេចក្តីសង្កេតទាំងនោះ អង្គជំនុំជម្រះនឹងត្រូវចេញគោលការណ៍ណែនាំចុងក្រោយសម្រាប់ការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញ រួមជាមួយនឹងបញ្ជីឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងករណីសមស្រប ក្នុងសំណុំរឿង ០០២។ នៅពេលនោះ អង្គជំនុំជម្រះនឹងស្នើសុំមតិយោបល់បន្ថែមពីភាគីដែលពាក់ព័ន្ធទៅនឹងឯកសារជាក់លាក់ណាមួយ ឬប្រភេទឯកសារណាមួយ។ ទីបី អង្គជំនុំជម្រះនឹងត្រូវធ្វើការពិនិត្យសាឡើងវិញនូវឯកសារសម្ងាត់ និងសម្ងាត់បំផុត និងធ្វើសេចក្តីសម្រេចលើការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញស្របតាមគោលការណ៍ណែនាំចុងក្រោយ។

## II. គោលការណ៍ណែនាំដែលស្នើឡើងសម្រាប់ការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញ

៣. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ឯកសារសម្ងាត់ចំនួន ១០៦.៨៣៦ និងសម្ងាត់បំផុតចំនួន ៤៧៦៣ បច្ចុប្បន្នក្នុងសំណុំរឿង ០០២ ដែលមានឯកសារ ១០៣.៩៤៩ ត្រូវ

បានដាក់ដោយសហចៅក្រមស៊ើបអង្កេត។ អង្គជំនុំជម្រះពិចារណាឃើញថា អត្ថិភាពនៃការសម្ងាត់នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ជាពិសេស ឯកសារទាំងនោះដែលត្រូវបានពិពណ៌នាក្នុងមាត្រា ៥.១(ក) (ខ) (គ) និង(ច) នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ថ្នាក់ឯកសារ គឺជាបញ្ហាគន្លឹះដែលត្រូវដោះស្រាយសម្រាប់គោលបំណងនៃការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះអញ្ជើញភាគីផ្តល់យោបល់ពាក់ព័ន្ធនឹងភាពចាំបាច់សម្រាប់អត្ថិភាពនៃការសម្ងាត់នៃឯកសារនោះនៅដំណាក់កាលនេះនៃសំណុំរឿង ០០២។

៤. បន្ថែមលើការពិចារណាពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងលើមាត្រា ៤, ៥ និង ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ថ្នាក់ឯកសារ អង្គជំនុំជម្រះតុលាការកំពូលស្នើឡើងនូវគោលការណ៍ណែនាំខាងក្រោមសម្រាប់អនុវត្តក្នុងដំណើរការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញ និងការគ្រប់គ្រងសំណុំរឿង ០០២៖

ក. ឯកសារខាងក្រោមដែលត្រូវរក្សា ឬដាក់ចំណាត់ថ្នាក់ជាសម្ងាត់មាន៖

i. ឈ្មោះ និងអាសយដ្ឋានទំនាក់ទំនងលម្អិតរបស់ជនជាប់ចោទ ដែលពុំមែនជាដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងក្នុងករណីដែលព័ត៌មាននេះត្រូវបានបញ្ចូលនៅក្នុងពាក្យបណ្តឹងរបស់ជនរងគ្រោះផងដែរ

ii. កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក និងខ្សែអាត់ថតសម្លេង/វីដេអូនៃសវនាការដែលបានធ្វើឡើង*ដោយសម្ងាត់* លើកលែងតែហេតុផលសម្រាប់រក្សាការសម្ងាត់លែងមានសុពលភាព

iii. ឯកសារដែលត្រូវបានរួមបញ្ចូលក្នុងសំណុំរឿងដទៃទៀត និងត្រូវបានដាក់ចំណាត់ថ្នាក់ជាសម្ងាត់។

ខ. ឯកសារដែលត្រូវបានដាក់ចំណាត់ថ្នាក់ជាសម្ងាត់បំផុត ជាគោលការណ៍នឹងត្រូវរក្សាការដាក់ចំណាត់ថ្នាក់បច្ចុប្បន្ន។ ឯកសារនេះរួមមាន៖

i. សំណើសុំវិធានការការពារ និងឯកសារពាក់ព័ន្ធ

ii. ឯកសារ និងព័ត៌មានដែលស្ថិតក្រោមវិធានការការពារ

iii. ព័ត៌មានពាក់ព័ន្ធទៅនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ

iv. ឯកសារដទៃទៀតដែលហេតុផលសម្រាប់ការដាក់ចំណាត់ថ្នាក់សម្ងាត់បំផុតនៅមានសុពលភាព

គ. ឯកសារណាមួយ ឬផ្នែកនៃឯកសារនោះដែលពុំស្ថិតក្នុងកថាខណ្ឌ (ក) ឬ (ខ) ខាងលើ ត្រូវបានចាត់ទុកជាសាធារណៈ

ឃ. ប្រសិនបើឯកសារមានផ្នែកខ្លះដែលជាសាធារណៈ និងខ្លះទៀតសម្ងាត់ ឬសម្ងាត់បំផុត ត្រូវអនុវត្តតាម មាត្រា ៣.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។

ង. ឯកសារសាធារណៈពុំត្រូវដាក់ជាសាធារណៈ នៅពេលដែលឯកសារនោះ៖ (ក) ត្រូវបានការពារដោយច្បាប់ជាធរមានស្តីពីសិទ្ធិថតចម្លង ឬ(ខ) "ដាក់ឱ្យស្ថិតក្រោមកិច្ចព្រមព្រៀងជាមួយតតីយជនដែលបានហាមឃាត់ការផ្សព្វផ្សាយជាសាធារណៈ [...] ដរាបណាទទួលបានការអនុញ្ញាតពីតតីយជន"[1]

ច. អង្គជំនុំជម្រះតុលាការកំពូលរក្សាយុត្តាធិការរបស់ខ្លួនក្នុងការដាក់ទណ្ឌកម្ម ស្របតាមវិធានផ្ទៃក្នុង លើការផ្សព្វផ្សាយគ្មានការអនុញ្ញាតនូវព័ត៌មានដែលត្រូវបានដាក់ចំណាត់ថ្នាក់

ឆ. ភាគីដែលពាក់ព័ន្ធ រួមទាំងសហព្រះរាជអាជ្ញា អង្គភាពគាំពារការការពារក្តីតំណាងឱ្យជនជាប់ចោទក្នុងសំណុំរឿង ០០២ អង្គភាពគាំពារជនរងគ្រោះតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឬផ្នែកកិច្ចការសាធារណៈ អាចស្នើសុំធ្វើចំណាត់ថ្នាក់សាឡើងវិញនូវឯកសារដែលសម្ងាត់ ឬសម្ងាត់បំផុត ក្រោយពីការបញ្ចប់នីតិវិធីធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនេះ។ ក្នុងករណីនេះ ភាគីពាក់ព័ន្ធគប្បីបង្ហាញនូវកាលៈទេសៈដែលធ្វើយុត្តិកម្មដល់ការដាក់ចំណាត់ឯកសារឡើងវិញនេះ។

## II. មតិយោបល់របស់ភាគី អង្គភាព និងផ្នែកនានានៃតុលាការ

៥. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលអញ្ជើញភាគីនៃអនុស្សរណៈបច្ចុប្បន្ន ដាក់សេចក្តីសង្កេតរបស់ខ្លួនលើ (i) គោលការណ៍ណែនាំដែលស្នើឡើងសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និង (ii) អត្ថិភាពនៃការសម្ងាត់នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការត្រឹមថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២។ ពុំមានការពន្យារពេលក្នុងការដាក់ឯកសារត្រូវបានអនុញ្ញាត និងពុំមាន

[1] មាត្រា ១២.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ចំណាត់ថ្នាក់ឯកសារ។

ការដាក់សារណាតបទៅនឹងសេចក្តីសង្កេតរបស់ភាគី អង្គភាព ឬផ្នែកដទៃទៀត ត្រូវបានអនុញ្ញាតឡើយ។

៦. ដោយសារស្ថានភាពបច្ចុប្បន្ននៃសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលស្នើសុំថា អង្គភាពគាំពារការការពារក្តី និងអង្គភាពគាំពារជនរងគ្រោះ នីមួយៗ ត្រូវប្រាកដថាមានការពិគ្រោះយោបល់ជាមួយមេធាវីការពារក្តី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

## I. Introduction

1. Pursuant to Article 12 of the Practice Direction on Classification and Management of Case-Related Information (Rev. 1) ("Practice Direction on Classification"), the Supreme Court Chamber, as "the last judicial office" seised of Case File in Case 002/19-09-2007-ECCC ("Case File 002"), has been tasked with a review of all documents currently classified as Confidential or Strictly Confidential on Case File 002, for the purposes of possible reclassification as Public. The purpose of this Memorandum is to establish an overall procedure, set out proposed guidelines and solicit input from interested parties regarding the reclassification process.

2. The Supreme Court Chamber will conduct its review of Case File 002 in three stages. First, in accordance with the present Memorandum, the Chamber has presented proposed guidelines for which it invites comments from the concerned parties, sections and units. Second, upon review of these observations, the Chamber will circulate final guidelines for reclassification together with a list of the Confidential and, where appropriate, Strictly Confidential documents on Case File 002. At that time, the Chamber will seek further input from the parties concerning any specific document or category of documents. Third, the Chamber will undertake a review of the Confidential and Strictly Confidential documents and make reclassification decisions in accordance with the final guidelines.

## II. Proposed Guidelines for Reclassification

3. The Supreme Court Chamber notes that, of 106,836 Confidential and 4763 Strictly Confidential documents currently on Case File 002, 103,949 were filed by the Co-Investigating Judges. The Chamber considers that the continuing

confidentiality of the judicial investigation, specifically those documents described in Article 5.1(a), (b), (c) and (f) of the Practice Direction on Classification, is the key issue to be resolved for the purposes of reclassification. The Chamber, therefore, invites comments concerning the continuing need for confidentiality of such documents at this stage of Case 002.

4. In addition to any considerations relating to the judicial investigation, and bearing in mind Article 4, 5 and 6 of the Practice Direction on Classification, the Chamber proposes the following guidelines for use during the reclassification process and the ongoing management of Case File 002:

a. The following documents shall remain, or be classified as Confidential:
   - iv. Names and contact details of victims who are not Civil Parties, including in cases where such information is included in victim complaints;
   - v. Written records, transcripts, and audio/visual recordings of hearings held *in camera*, unless the reasons for maintaining confidentiality are no longer valid;
   - vi. Documents which are also included in other existing Case Files and classified as confidential.

b. Documents which are classified Strictly Confidential will in principle retain their present classification. These include:
   - v. Requests for protective measures and associated documents;
   - vi. Documents and information subject to protective measures;
   - vii. Information concerning the health of a Suspect, Charged Person or Accused;
   - viii. Other documents where the reasons for reclassification as strictly confidential persists.

c. Any document or part thereof which does not fall within paragraphs (a) or (b), above, shall be declassified as public.

d. If a document consists of a portion which ought to be public and a portion which ought to be classified as confidential or strictly confidential, Article 3.3 of the Practice Direction on Classification applies.

e. Public documents shall not be subject to public dissemination where they are:

(a) protected by copyright applicable laws; or (b) "subject to agreement with a third party that prohibits dissemination [...] unless permission is granted by the third party."[2]

f. The Supreme Court Chamber retains jurisdiction to sanction, in accordance with the Internal Rules, any unauthorised disclosure of classified information.

g. Any concerned party, including the Co-Prosecutors, the Defence Support Section acting on behalf of the Accused in Case 002, the Victim Support Section acting on behalf of the Civil Parties in Case 002, the Witness and Experts Support Unit, or the Public Affairs Section, may seek reclassification of any document which retains its Confidential or Strictly Confidential status following the conclusion of the reclassification procedure. In such a case, the concerned party should demonstrate changed circumstances justifying the reclassification.

## III. Input from the Parties, Sections and Units of the Court

5. The Supreme Court Chamber hereby invites the addressees of the present Memorandum to submit their observations on (i) the proposed guidelines for reclassification; and (ii) the continuing confidentiality of the judicial investigation by **22 August 2022**. No extensions of time to file will be granted, and no responses to the observations of other parties, sections or units will be permitted.

Given the current status of Case 002, the Supreme Court Chamber requests that the Defence Support Section and the Victims Support Section, respectively, ensure consultation with Defence Counsel and Civil Party lawyers.

[2] Practice Direction on Classification, Article 12.3.